# ពត៌មានសំរាប់អ្នកដឹកនាំ បព្វជិតភាព និង អង្គការជំនួយ ស្តីអំពីកម្មវិធីសិក្សា

ចាប់ពីឆ្នាំ 2005 ដល់ ឆ្នាំ 2008

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

## សេចក្តីណែនាំ

បញ្ជីឯកសារនេះ មានរាយនាមសំភារៈកម្មវិធីហ្វឹកហ្វឺន (1 ) អាចប្រើប្រាស់បានក្នុងផ្ទះ និង (2) កាលវិភាគសំរាប់ប្រើប្រាស់ក្នុង អង្គភាពសាសនាចក្រ សំរាប់ ឆ្នាំ 2005 ដល់ ឆ្នាំ 2008។ សេចក្តីចំលងអំពីសេចក្តីប្រកាសនេះ នឹងត្រូវប្រគល់ ទៅឱ្យអ្នកដឹកនាំ បព្វជិតភាព និងអង្គការជំនួយ។ ហើយវានឹងត្រូវបានពិនិត្យនៅក្នុងការប្រជុំ ក្រុមប្រឹក្សាប្រចាំវួដ។

## សេចក្តីសង្ខេប នៃកម្មវិធីសាសនាចក្រ

សាសនាចក្របានបង្កើត ឯកសារជាច្រើនសំរាប់កម្មវិធីនានា ដើម្បីជួយសមាជិក អោយរៀន និងរស់នៅតាមដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ។ ព្រះគម្ពីរ និង ការបង្រៀននៃព្យាការី គឺជាមូលដ្ឋានគ្រឹះនៃកម្មវិធីនេះ។

កម្មវិធីមូលដ្ឋានគ្រឹះរបស់សាសនាចក្រ ផ្អែកលើមូលដ្ឋានគ្រឹះពីរគឺៈ *កម្មវិធីជាមូលដ្ឋាន និងកម្មវិធីជាទូទៅ*។

*កម្មវិធីជាមូលដ្ឋាន* គឺប្រើសំរាប់កន្លែងណាដែលសាសនាចក្រ ទើបនឹងចាប់ផ្តើមបង្កើតថ្មីៗ នៅក្នុងតំបន់ រឺកន្លែងដែល *ឯកសារ ទូទៅ* របស់កម្មវិធីសិក្សាជាទូទៅ មិនទាន់មាន ឬក៏មិនទាន់បកប្រែជាភាសាខ្លួន។ តារាងដែលបង្ហាញអំពីកាលវិភាគ និង *កម្មវិធីសិក្សាជាមូលដ្ឋាន* គឺមាននៅ ទំព័រទី ០០។

*កម្មវិធីសិក្សាជាទូទៅ* គឺពឹងផ្អែកទៅលើ *កម្មវិធីសិក្សាជាមូលដ្ឋាន* ហើយត្រូវប្រើនៅក្នុងតំបន់ដែលសាសនាចក្រ បានរៀបចំល្អ។ តារាងដែលបង្ហាញពីកាលវិភាគ ហើយសំរាប់ *កម្មវិធីសិក្សាជាទូទៅ* គឺមាននៅក្នុង ទំព័រទី ០០។

គណៈប្រធានប្រចាំតំបន់ ដែលមានការអនុញ្ញាតឱ្យមានការទាក់ទងជាមួយនឹង កុមសារក៍ដប់ពីរ អាចសំរេចដើម្បីឱ្យ ប្រើប្រាស់ *កម្មវិធីសិក្សាជាមូលដ្ឋាន* នៅក្នុងតំបន់ និងដែលរៀបបានល្អ ហើយភាសានឹងអាចជួយបំរើសមាជិកនៅទីនោះ បានល្អប្រសើរ ផងដែរ សំរាប់ *កម្មវិធីសិក្សាជាទូទៅ*។

## ការទទួល និងការប្រើប្រាស់ ឯកសារសំរាប់ កម្មវិធីសិក្សា

អំឡុងពេលត្រីមាសនៃឆ្នាំនីមួយៗ អង្គភាពសាសនាចក្របានទទួល (1) Annual Curriculum Order (ទំរង់បែបបទ សំរាប់កុម្មង់យក កម្មវិធីសិក្សាប្រចាំឆ្នាំ) ដើម្បីស្នើរសុំសំភារៈ សំរាប់ឆ្នាំបន្ទាប់ ឬ (2) ការបញ្ជូនសំភារៈសំរាប់ឆ្នាំបន្ទាប់ ដោយមានភ្ជាប់នូវទំរង់បែប បទបន្ថែមទៀត បើចាំបាច់។ ស្មៀនប្រចាំវួដ ឬ ទីប្រឹក្សាម្នាក់របស់គាត់ អាចជួយ អ្នកដឹកនាំ បព្វជិតភាព និងអង្គការជំនួយ អោយបំពេញ ទំរង់បែបបទនៃការការស្នើរសុំ ហើយទទួលយកសំភារៈដែលត្រូវការ។ ប្រភពធនធាននៃ កម្មវិធីសិក្សាជាច្រើន ក៏អាច មាននៅក្នុង បណ្ណាគារ សាលាប្រជុំ ផងដែរ។

អ្នកដឹកនាំគួរតែមើលឃើញថា រាល់គ្រូបង្រៀនទាំងអស់បានប្រើប្រាស់ សំភារៈរបស់កម្មវិធី។ គួរតែលើកទឹកចិត្តគ្រូបង្រៀន ឱ្យបង្រៀនមេរៀន តាមការរៀបចំ ដែលបានបង្ហាញនៅក្នុងសៀវភៅសិក្សា។

ឯកសារណែនាំនៅក្នុងបញ្ជី នេះមិនមានគ្រប់ភាសាទាំងអស់ទេ។ បើអ្នកចង់ស្វែងរកឯកសារដែលអាចប្រើបាន ក្នុងភាសាជាក់លាក់ណាមួយនោះ ចូរទាក់ទងជាមួយមជ្ឈមណ្ឌលសេវាកម្ម នៅក្នុងតំបន់របស់អ្នក។

## កម្មវិធីសំរាប់សមាជិកពិការ

អ្នកដឹកនាំគួរតែប្រាកដថា សមាជិកដែលពិការ គឺដឹងពី កម្មវិធី សំភារៈសាសនាចក្រ ដែលអាចបំពេញ សេចក្តីត្រូវការរបស់ពួកគេ។ ពត៌មានបន្ថែមពី ឯកសារនេះ សូមមើល *Church Materials Catalog* (សៀវភៅរាយឈ្មោះឯកសាររបស់សាសនាចក្រ) ឬទាក់ទងជាមួយ មជ្ឈមណ្ឌលសេវាកម្ម នៅក្នុងតំបន់របស់អ្នក។

## ការកែលំអគ្រូបង្រៀន

អ្នកដឹកនាំ បព្វជិតភាព និង អង្គការជំនួយគឺជាអ្នកដែល មានការទទួលខុសត្រូវចំពោះគុណភាពបង្រៀន នៅក្នុងអង្គការរបស់ ពួកគេ។ ប្រភពធនធានសំរាប់ ឯកសារកែលំអគ្រូបង្រៀន រួមមានសៀវភៅ *Improving Gospel Teaching: A Leader's Guide* (៣៥១១៧); *Teaching, No Greater Call* (៣៦១២៣); "Gospel Teaching and Leadership," ផ្នែកទី 16 នៃ *Church Handbook of Instructions, Book 2* (៣៥៩០៣) និង *សៀវភៅណែនាំការបង្រៀន* (34595 258)។

អ្នកដឹកនាំត្រូវប្រាកដថា គ្រូបង្រៀនទាំងអស់មាននៃសៀវភៅ *Teaching, No Greater Call* និង "Gospel Teaching and Leadership" នៅក្នុង *Church Handbook of Instructions.*

អ្នកសំរបសម្រួល កែលំអគ្រូបង្រៀនប្រចាំវួដ គឺជាប្រភពធនធានមួយយ៉ាងសំខាន់សំរាប់ការកែលំអគ្រូបង្រៀន។ គាត់បំរើនៅ ក្រោមការគ្រប់គ្រងរបស់ប្រធានសាលាថ្ងៃអាទិត្យ ប៉ុន្តែត្រូវធ្វើការជាមួយ គ្រប់អង្គការទាំងអស់នៅក្នុងវួដ។

---

## កម្មវិធីសិក្សានៅតាម គេហដ្ឋាន

សាសនាចក្របានផលិតឯកសារជាច្រើនសំរាប់ជួយសមាជិករៀន បង្រៀន និង រស់នៅតាមដំណឹងល្អ នៅក្នុងគេហដ្ឋាន។ ឯកសារ ជា ច្រើនគួរតែមាននៅតាមគេហដ្ឋាន (ដែលមាននៅក្នុងភាសារបស់គេ)។ អ្នកដឹកនាំគួរព្យាយាម ដោយប្រាកដថា សមាជិកថ្មីមានឯកសារទាំងនេះ។

ព្រះគម្ពីរ
ទស្សនាវដ្តី នៃសាសនាចក្រ
*គោលការណ៍ទាំងឡាយ នៃព្រះសិក្ខាបទ* (31110 258 ) ឬ *Gospel Fundamental* (31129)
*ទំនុកតំកើងព្រះ និង ចំរៀងកុមារាកុមារី* (33438 258)
*ក្រុមគ្រួសារៈ សេចក្តីប្រកាស់ដល់ពិភពលោក* (35602 258)
*ព្រះគ្រីស្ទដ៏មានព្រះជន្មរស់នោះ ទីបន្ទាល់ នៃពួកសាវក័* (36299 258)
*សៀវភៅណែនាំក្នុងក្រុមគ្រួសារ* (31180 258)
*Family Home Evening Resource Book* (31106)
*សៀវភៅណែនាំ សំរាប់ការបង្រៀន* (34595 258)

ឯកសារបន្ថែមផ្សេងទៀត ក៏អាចប្រើបានក្នុងការបង្រៀនដំណឹងល្អ នៅតាមគេហដ្ឋានផងដែរ។ ឯកសារទាំងនេះរួមទាំង ទូរទស្សន៍ កាសែត ការសែតស្តាប់សម្លេង រូបភាព និងរូបភាពផ្សេងៗទៀត ព្រះគម្ពីរទាំងឡាយ និងឯកសារ បោះពុម្ពផ្សេងៗ ទៀត

សំរាប់ កុមារ យុវជនយុវនារី និង យុវជនយុវនារី វ័យទំទង់។ សំរាប់ពត៌មានបន្ថែម សូមមើល *Church Materials Catalog (សៀវភៅរាយឈ្មោះឯកសារ)* ឬ *Family Resource Catalog (សៀវភៅរាយឈ្មោះឯកសារសំរាប់គ្រួសារ)*។ សូមបើកមើល www.ldscatalog.com នៅក្នុងអ៊ីនធើណែត ឬធ្វើការទាក់ទងជាមួយ មជ្ឈមណ្ឌលសេវាកម្ម នៅក្នុងតំបន់ របស់អ្នក។ ប្រភពធនធានទាំងនេះភាគច្រើន ក៏មានផងដែរនៅក្នុង “វគ្គ្យេ កិម ៗកងេអ” ក្នុងផ្នែកនៃ www.lds.org.

---

## កម្មវិធីសំរាប់សាសនាចក្រទាំងមូល

ឆ្នាំនៃកម្មវិធីសំរាប់ពិភពលោកទាំងមូលនឹងចាប់ផ្តើមនៅ ថ្ងៃ ទី 1 ខែ មករា។ កុមារ និង យុវជន យុវនារី បានរៀបចំតាមអង្គការ ដោយអាស្រ័យ លើអាយុរបស់ពួកគេ លើកាលបរិច្ឆេទ។

## អំណាចបព្វជិតភាពម៉ិលគីស្សាដែក និង សមាគមសង្គ្រោះស្ត្រី

ថ្ងៃអាទិត្យភាគច្រើន អ្នកបព្វជិតភាពម៉ិលគីស្សាដែក និងបងប្អូនស្រី ក្នុងថ្នាក់សមាគមសង្គ្រោះស្ត្រី មានការសិក្សា ប្រធានបទដូចគ្នា និងប្រើប្រាស់ឯកសារដូចគ្នា។ ទោះបីជាយ៉ាងក៏ដោយ ពួកគេត្រូវប្រជុំដាច់ដោយឡែកពីគ្នាក៏ដោយ។

**នៅសប្តាហ៍ទីមួយ។** អ្នកដឹកនាំបព្វជិតភាពម៉ិលគីស្សាដែក ប្រើការប្រជុំនេះ ដើម្បី បង្រៀន សមាជិកក្រុមរបស់ពួកគេ ពីភារកិច្ច និង ជួយពួកគេ ឱ្យចូលរួមយ៉ាងសកម្មជាមួយ ការងារបព្វជិតភាព។ អ្នកដឹកនាំសមាគមសង្គ្រោះស្ត្រី ប្រើការប្រជុំនេះ ដើម្បីបង្រៀនបង ប្អូនស្រីទាំងឡាយ អំពីគោលបំណងនៃសមាគមសង្គ្រោះស្ត្រី និង កិច្ចការដ៏ពិសិដ្ឋ នៃថ្នាក់ នីមួយៗ។

ប្រធានបទសំរាប់ការប្រជុំនេះ រួមទាំងការពង្រឹង អាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារ ការបង្រៀនតាមផ្ទះ និង ការសួរសុខទុក្ខតាម ផ្ទះ ការបំរើ កិច្ចការអ្នកផ្សាយសាសនា ការធ្វើឱ្យសកម្មឡើងវិញ ការរាប់អាន និងសុខមាលភាព ខាងវិញ្ញាណ និង ខាងលោកីយ និង ព្រះវិហារបរិសុទ្ធ និងប្រវត្តិពង្សាវតា។

អ្នកដឹកនាំក្រុមអែលឌើរ ក្រុមសង្ឃជាន់ខ្ពស់ សមាគមសង្គ្រោះ រៀបចំផែនការណ៍នៃការប្រជុំនេះ ដើម្បីជាផលប្រយោជន៍សំរាប់ អង្គការរបស់ពួកគេផ្ទាល់។ មេរៀនទាំងនេះ គឺត្រូវបង្រៀនដោយ អ្នកដឹកនាំ ដោយប្រើធនធានឯកសារ ដែលមានចុះក្នុងបញ្ជី ទំព័រ 4 និង 5។ អ្នកដឹកនាំ គួរតែរៀបចំគម្រោងការប្រជុំនេះ ដោយការអធិស្ឋានយ៉ាងស្មោះត្រង់ ស្វែងរកសេចក្តីត្រូវការរបស់ សមាជិក និងពិចារណា ដើម្បីបំពេញសេចក្តីត្រូវការទាំង នោះ។

**នៅសប្តាហ៍ទីមួយ** ក្រុម និងក្រុមប្រជុំជាក្រុម គួរតែជួបគ្នាជាទៀងទាត់ រួមទាំងពេលរៀបចំផែនការណ៍សំរាប់ផ្តល់ការបំរើ និងការងារ ផ្សេងទៀតនៃក្រុម។ ការប្រជុំនេះក៏រួមបញ្ចូលផងដែរ នូវពេលវេលាសំរាប់ហ្វឹកហ្វឺន, ការបង្ហាញ ពីរបៀប ធ្វើពិធីការ, ការរៀបចំគម្រោងដើម្បី ជួយអ្នកដទៃ, ការផ្តល់កិច្ចការ និងធ្វើរបាយការណ៍ ពីកិច្ចការដែលបានចាត់ឱ្យកាលពីមុន។

សប្តាហ៍ទីមួយ ការប្រជុំ សមាគមសង្គ្រោះស្ត្រី គួរតែជួយ បង ប្អូន ស្រី ឱ្យក្លាយជាសមាជិកមានសេចក្តីស្មោះត្រង់ និង ប្រពន្ធ ម្តាយ កូនស្រី និង អ្នកជិតខាង កាន់តែល្អប្រសើរឡើង។ គណៈប្រធានអាចយកពេលចែកចាយ ការណែនាំ ដែលយកមកពីការពិភាក្សា ពីអ្នកដឹកនាំបព្វជិតភាព នៅក្នុងការប្រជុំ សុខមាលភាពរបស់វួដ និង ការប្រជុំការប្រឹក្សា វួដ។ ពួកគេអាចអនុញ្ញាតឱ្យបង ប្អូនស្រី ចែករំលែកទីបន្ទាល់របស់ ពួកគេផងដែរ។

**សប្តាហ៍ទីពីរ និង ទីបី ។** សំរាប់ក្រុមដែលប្រើ កម្មវិធីមូលដ្ឋាន ការណែនាំក្នុង សប្តាហ៍ទាំងនេះ គឺយកចេញមកពី សៀវភៅ*ភាតព្វកិច្ច និងពរទាំងឡាយនៃបព្វជិតភាព* និង *សៀវភៅសត្តិកនារីទិវាចុងក្រោយ*។ សំរាប់ក្រុមប្រើប្រាស់ កម្មវិធីទូទៅ ការណែនាំ យកចេញ មកពី សៀវភៅ*ការបង្រៀន នៃប្រធាន សាសនាចក្រ* ក្នុងពេលបច្ចុប្បន្ន។ សមាជិកម្នាក់ៗគួរតែ បានទទួលសៀវភៅនេះ មួយ ក្បាល ដើម្បីប្រើប្រាស់សំរាប់ ការណែនាំ។

អ្នកដឹកនាំក្រុម អែលឌើរ ក្រុមសង្ឃជាន់ខ្ពស់ និង សមាគមសង្គ្រោះស្ត្រី គួរតែរៀបចំគំរោង ផែនការណ៍នៃការប្រជុំនេះសំរាប់ អង្គការរបស់ពួកគេផ្ទាល់។ មេរៀនត្រូវបង្រៀនដោយអ្នកដឹកនាំទាំងនេះ ឬដោយ ក្រុម ឬ ក្រុមអ្នកស្តាបនា ឬ គ្រូបង្រៀនថ្នាក់សមាគម សង្គ្រោះស្ត្រី។

ប្រសិនបើ សង្កាត់មានសន្និសីទ ឬការប្រជុំផ្សេងទៀតដែលច្រានចោលការបង្រៀននៃមេរៀននេះ អ្នកដឹកនាំប្រចាំតំបន់ ជាអ្នក សម្រេចចិត្តថា តើត្រូវបង្រៀននៅសប្តាហ៍មួយផ្សេងទៀត។ មេរៀនត្រូវបង្រៀនតាមលំដាប់លំដោយ ដែលមាននៅក្នុង សៀវភៅ។

**សប្តាហ៍ទីបួន —ការបង្រៀនសំរាប់ពេលវេលារបស់យើង។** ប្រធានបទ និង ឯកសារសំរាប់សប្តាហ៍នេះ បានរើសទុករួចហើយ ដោយ គណៈប្រធានទីមួយ ជាទូទៅ និង ទស្សនាវដ្តី *Ensign* និង *លៀអាហូណា* ដែលចេញផ្សាយសំរាប់ ខែ ឧសភា និង ខែ វិច្ឆិកា។

អ្នកដឹកនាំក្រុម អែលឌើរ ក្រុមសង្ឃជាន់ខ្ពស់ និង សមាគមសង្គ្រោះស្ត្រី គួរតែរៀបចំផែនការណ៍ នៃការប្រជុំនេះ ដើម្បីជាផល ប្រយោជន៍ សំរាប់ សំរាប់អង្គការរបស់ពួកគេផ្ទាល់។ មេរៀនត្រូវបង្រៀនដោយអ្នកដឹកនាំទាំងនេះ ឬដោយ ក្រុម ឬ ក្រុមអ្នក ស្តាបនា ឬ គ្រូបង្រៀនថ្នាក់ សមាគមសង្គ្រោះស្ត្រី។

**សប្តាហ៍ទី ប្រាំ (បើសិនជាមាន)** ប្រធានបទសំរាប់ការប្រជុំនេះ គឺត្រូវបានកំណត់ដោយ គណៈប្រធានប៊ីស្សប ដើម្បីតំរូវទៅតាម សេចក្តីត្រូវការក្នុងតំបន់។ នៅក្នុងសប្តាហ៍នេះក្រុមអែលឌើរ និង ក្រុមសង្ឃជាន់ខ្ពស់ ប្រហែលជាជួបគ្នា ឬចូលរួមជាមួយសមាគម សង្គ្រោះស្ត្រី។

## បព្វជិតភាព អើរ៉ុន និង យុវនារី

ក្រុមបព្វជិតភាព អើរ៉ុន ជាធម្មតា ប្រជុំបែកគ្នាជាមួយ ការប្រជុំក្រុម ថ្ងៃសាលាអាទិត្យ និង ម៉ោងសិក្សា។ ទោះជាយ៉ាងណា ក៏ដោយពួកគេ នឹងរួមបញ្ចូលគ្នាពេលដែលមានបព្វជិតភាពអើរ៉ុន តែពីរ បីនាក់—ដែលនៅក្នុងក្រុមយុវជន។ មានគោល ការណ៍ណែនាំឆ្លើយតបដូច ថ្នាក់យុវនារីដែរ។

នៅក្នុងអង្គភាព ប្រើប្រាស់ កម្មវិធីមូលដ្ឋាន ថ្នាក់យុវជន អាចចូលរួមប្រជុំជាមួយអ្នកកាន់ បព្វជិតភាព ម៉ិលគីស្សាដែក ប្រសិនបើពួកគេមានចំនួន តិចតួច។ យុវនារី នៅក្នុងវគ្គនេះអាចចូលរួមប្រជុំជាមួយសមាគមសង្គ្រោះស្ត្រី ប្រសិនបើពួកគេ មានចំនន្ទ តិចតួច។

អ្នកកាន់បព្វជិតភាព អើរ៉ុន និង យុវនារី ត្រូវបានបង្រៀន យកចេញ ពីបញ្ជី សៀវភៅសិក្សានៅទំព័រ 00 និង 00។ អ្នកដឹក នាំអាចអញ្ជើញពួកយុវជន និង យុវនារីឱ្យជួយបង្រៀនមេរៀនខ្លះៗ។ ធនធានផ្សេងទៀតសំរាប់បង្រៀនរួមមាន ដើម្បីគុណភាពនៃយុវជនយុវនារី (36550 258) ស្មោះត្រង់ចំពោះសេចក្តីជំនឿ (36863 258) និង ទស្សនាវដ្តី របស់សាសនាចក្រ។ លេខចេញផ្សាយ សំរាប់ខែ ឧសភា និង វិច្ឆិកា របស់ រឃឿ រក្រ, រិាងណិ និង *លៀអាហូណា* ហើយក៏រួមបញ្ចូលផងដែរ នូវការណែនាំពីប្រភព ធនធាន ដែលផ្តល់ សេចក្តីយោង សំរាប់អត្ថបទរបស់ ទស្សនាវដ្តី សាសនាចក្រ និងឯកសារផ្សេងទៀត ដែលសំរាប់ធ្វើឱ្យមេរៀន ដែលតែងតែមាន ភាពល្អប្រសើរ។

## អង្គការបឋមសិក្សា

អ្នកដឹកនាំគួរបែងចែកក្រុមកុមារចូលក្នុងថ្នាក់ អង្គការបឋមសិក្សា អាស្រ័យលើអាយុរបស់ពួកគេនៅក្នុង ខែ មករា ថ្ងៃ ទី1 ។ ប្រសិនបើមានចំនួនជាក់លាក់នៃកុមារ ត្រូវបំបែកថ្នាក់ ដែលគួរតែរៀបចំក្រុមតាមអាយុនីមួយៗ។ នៅកន្លែងណាដែល ថ្នាក់រៀន ឬគ្រូបង្រៀន ពុំសូវមានច្រើននោះ កុមារដែលមានអាយុខុសគ្នា អាចដាក់ក្នុងក្រុមជាមួយគ្នា។

ចំពោះកន្លែងដែលអាចប្រើប្រាស់ កម្មវិធីទូទៅបាន គួតែមានថ្នាក់ទារកដ្ឋាន សំរាប់កុមាដែលមានអាយុចូល 18 ខែ។ ចុះឈ្មោះ កុមាក្នុងថ្នាក់នេះ គឺជាការជ្រើសរើស នៃឪពុកម្តាយ។ កុមារដែលមានអាយុ 2 ឆ្នាំនៅក្នុង ថ្ងៃ ទី 1 ខែ មករា ត្រូវបន្ត នៅក្នុង ថ្នាក់ទារកដ្ឋាន

រហូតដល់ចុងឆ្នាំ។ កុមារដែលមានអាយុ 3 ឆ្នាំនៅក្នុង ខែ មករា ថ្ងៃ ទី 1 ត្រូវចូលរួម ថ្នាក់ Sunbeam 4 ឬ ចូលរួមជាមួយថ្នាក់ដែលកុមារមានអាយុក្មេង ជាងគេ។

កុមារបង្រៀនតាម សៀវភៅសិក្សា ដែលបង្ហាញក្នុងតារាង ទំព័រ 4 និង 5។ ធនធានបង្រៀនផ្សេងៗទៀតរួមទាំង ទស្សនាវដ្ដី របស់ សាសនាចក្រ ព្រះគម្ពីររូបភាព កញ្ចប់រូបភាពនៃដំណឹងល្អ និង *ចំរៀងកុមាររាកុមារី។*

ពេលសមរម្យ ចូរឱ្យកុមារដែលមានអាយុតិចជាងឱ្យចូលរួម ពេលវេលាចែកចាយ អំឡុងពេលដែលកុមារ ធំៗ ចូលក្នុងថ្នាក់។ រយៈពេលពាក់កណ្ដាលនៃកម្មវិធីថ្នាក់អង្គការ បឋមសិក្សា ក្រុមទាំងពីរផ្លាស់ប្ដូទីកន្លែង។ ពេលដែល មានចំនួនតិចតួចនាក់ ក្រុមទាំងពីរ អាចប្រជុំរួមគ្នា។ ប្រសិនបើក្រុមទាំងពីរបំបែកគ្នា ពេលវេលាចែកចាយសំរាប់កុមារធំៗ គួរតែ ប្រព្រឹត្តទៅ ក្នុងអំឡុងពេល ដូចគ្នានឹងម៉ោងរៀនរបស់យើង បព្វជិតភាពអើរ៉ុន និង ថ្នាក់យុវនារី។

កុមារដែលមានអាយុ 12 ឆ្នាំ ក្នុងអំឡុងពេលនៃឆ្នាំ ត្រូវបន្តចូលរួមថ្នាក់អង្គការ បឋមសិក្សារបស់ពួកគេ រហូតដល់ខែ មករាឆ្នាំ ក្រោយ។ ទោះជាយ៉ាងណាក៏ដោយ អំឡុងពេល ពេលវេលាចែកចាយ ពួកគេចាប់ផ្ដើមចូលរួមប្រជុំ ក្នុងថ្នាក់ ក្រុមបព្វជិតភាព អើរ៉ុន ឬ យុវនារី។

## ថ្នាក់សាលាថ្ងៃអាទិត្យ

ថ្នាក់សាលាថ្ងៃអាទិត្យសំរាប់ មនុស្សពេញវ័យ និង សំរាប់ យុវជន យុវនារី ដែល មានអាយុ 12 ឆ្នាំ នៅក្នុង ថ្ងៃ ទី 1 ខែ មករា ។ កុមារដែលមានអាយុ 12 ឆ្នាំ ក្នុង អំឡុងពេលនៃឆ្នាំ ត្រូវបន្តនៅក្នុងថ្នាក់អង្គការបឋមសិក្សារបស់ពួកគេ អំឡុងពេល ថ្នាក់ សាលា ថ្ងៃអាទិត្យ។

ពេលដែលមានចំនួនយុវជន យុវនារី គ្រប់គ្រាន់ ចូរបំបែកថ្នាក់ ដោយរៀបចំក្រុមតាម អាយុ។ នៅទីណាដែលពួក យុវជន យុវនារី មានចំនួនតិចតួច ឬក៏ បន្ទប់រៀន ឬគ្រូបង្រៀនចំនួន មានតិចតួច យុវជន យុវនារី ដែលមានអាយុខុសគ្នា អាចចូលរួមជាមួយ គ្នា។

វគ្គសិក្សា ថ្នាក់សាលាថ្ងៃអាទិត្យ និងធនធានសំរាប់ការបង្រៀនពួកគេ គឺមានបង្ហាញ នៅក្នុងតារាង ទំព័រ 00 និង 00។

## វគ្គសិក្សាដែលអាចជ្រើសរើសបាន

ពត៌មានបន្ថែម វគ្គសិក្សាដែលមានការជ្រើសរើស សូមមើលលើតារាង ដែលមាន នៅក្នុងទំព័រ 00 និង 00។ វគ្គសិក្សា ទាំងនេះបានធ្វើឡើង ទៅតាមសេចក្ដីត្រូវការ ក្រោម ការដឹកនាំ នៃគណៈប៊ីស្សព។ ពួកគេបានធ្វើកម្មវិធីនេះឡើង ទៅតាមពេល អំណោយផល អ្នកចូលរួមដោយ រួមទាំងអំឡុងពេលនៃ ថ្នាក់សាលាថ្ងៃអាទិត្យ។

# កម្មវិធីជាមូលដ្ឋាន សំរាប់អង្គភាពសាសនាចក្រ[1]

(ប្រើប្រាស់នៅកន្លែងដែល សាសនាចក្រ ទើបតែបង្កើតថ្មីៗ ឬពេលដែលមិនទាន់មាន ឯកសារសំរាប់បង្រៀនតាម កម្មវិធីទូទៅ)។

| ការរៀបចំអង្គការ | សៀវភៅសិក្សា និងប្រភពធនធាន | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|
| **បព្វជិតភាព មិុលគីស្សាដែក និង សមាគមសង្គ្រោះស្ត្រី** | **សប្តាហ៍ទីមួយ**<br>អ្នកដឹកនាំអាចពឹងផ្អែកទៅលើឯកសារដូចតទៅ នៅពេលដែលមាននៅក្នុងភាសារបស់ខ្លួនៈ ព្រះគម្ពីរ ទស្សនាវដ្តីនៃសាសនាចក្រ *សៀវភៅណែនាំ សំរាប់បព្វជិតភាព ថ្នាក់ជំនួយ* (31178 258) *សៀវភៅណែនាំ ក្រុមគ្រួសារ* (31180 258) *សៀវភៅណែនាំ សំរាប់ការបង្រៀន* (34595 258) *ករណីកិច្ចនិងពរ នៃបព្វជិតភាព ផ្នែក ក* (31111 258) និង *ផ្នែក ខ* (31112 258) *សន្តិកនារីទិវាចុងក្រោយ ផ្នែក ក* (31113 258) និង *ផ្នែក ខ* (31114 258) និង *គោលការណ៍ទាំងឡាយ នៃព្រះសិក្ខាបទ* (31110) ឬ *គ្រឹះនៃដំណឹងល្អ* (31129)។ | • | • | • | • |
| | **សប្តាហ៍ទីពីរ និង ទីបី**<br>*កាតព្វកិច្ច និងពរទាំងឡាយ នៃបព្វជិតភាព ភាគ ក* (31111 258) និង<br>*សន្តិកនារីទិវាចុងក្រោយ ផ្នែក ក* (31113 258) | • | • | | |
| | *កាតព្វកិច្ច និងពរទាំងឡាយ នៃបព្វជិតភាព ផ្នែក ខ* (31112 258) និង<br>*សន្តិកនារីទិវាចុងក្រោយ ផ្នែក ខ* (31114 258) | | | • | • |
| | **សប្តាហ៍ទីបួន**<br>ឯកសារនៃការបង្រៀនសំរាប់ជំនាន់របស់យើង ត្រូវបានជ្រើសរើសទុកដោយ គណៈប្រធានទីមួយ (ប្រសិនបើឯកសារនេះ មិនមាននៅក្នុង ភាសារបស់អ្នកទេ អ្នកអាចប្រើសារលិខិតមកពីគណៈប្រធានទីមួយ និងសារលិខិតការសួរសុខទុក្ខតាមផ្ទះ។ ឯកសារ ទាំងនេះបានបោះពុម្ព នៅក្នុងទស្សនាវដ្តី នៃសាសនាចក្រ ឬផ្ញើទៅកាន់តំបន់ដែលទស្សនាវដ្តី មិនទាន់មាន។) | • | • | • | • |
| | **សប្តាហ៍ ទី 5 ៈ** ប្រធានបទ និង ធនធានដែលបានកំណត់ទុកដោយគណៈប្រធានទីមួយ | • | • | • | • |
| **បព្វជិតភាព អេរ៉ុន និង យុវនារី** | **សប្តាហ៍ទី 1 ទី 4 និង ទី 5**<br>*បព្វជិតភាព អេរ៉ុន ភាគ 1* (34820 258) ឬ *យុវនារី ភាគ 1* (34823 258)។ ចូរបង្រៀនមេរៀនតាមលំដាប់លំដោយ ដើម្បីឱ្យចប់ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់មក បង្រៀនសាឡើងវិញ។ [2] | • | • | • | • |
| | **សប្តាហ៍ទី 2 និង ទី3**<br>*កាតព្វកិច្ច និងពរទាំងឡាយ នៃបព្វជិតភាព ផ្នែក ក* (31111 258) និង<br>*សន្តិកនារីទិវាចុងក្រោយ ផ្នែក ក* (31113 258) ។ | • | • | | |
| | *កាតព្វកិច្ច និងពរទាំងឡាយ នៃបព្វជិតភាព ផ្នែក ខ* (31112 258) និង<br>*សន្តិកនារីទិវាចុងក្រោយ ផ្នែក ខ* (31114 258) | | | • | • |
| **ថ្នាក់អង្គការ បឋមសិក្សា** | **អាយុ 3 ឆ្នាំ**<br>*អង្គការបឋមសិក្សា ទី1ៈ ខ្ញុំជាកូនរបស់ព្រះ* (34969 258) | • | • | • | • |
| | **អាយុ 4–7 ឆ្នាំ**<br>*អង្គការបឋមសិក្សាទី 2ៈ ជ្រើសរើស ផ្លូវត្រូវ ក* (34484 258) | | • | | • |
| | *អង្គការបឋមសិក្សាទី 3ៈ ជ្រើសរើស ផ្លូវត្រូវ ខ* (34499 258) | • | | • | |
| | **អាយុ 8–11**<br>*New Testament* (34604) | • | | • | |
| | *ព្រះគម្ពីរ មរមន* (34594 258) | | • | | • |
| **សាលាថ្ងៃអាទិត្យ** | **អាយុ 12–ពេញវ័យ**<br>*គោលការណ៍ទាំងឡាយ នៃព្រះសិក្ខាបទ* (31110 258) ឬ Gospel Fundamentals (31129)។ វគ្គសិក្សានេះសំរាប់ សាសនាគន់កាវិ និង អ្នក ដែលចង់ដឹងពី សេចក្តីណែនាំនៃដំណឹងល្អ ជាមូលដ្ឋាន។ | • | • | • | • |
| | *សៀវមរមន សៀវភៅគោលលទ្ធិនៃដំណឹងល្អ សំរាប់គ្រូបង្រៀន* (35683 258) | | | | • |
| | *សៀវភៅសិក្សាសំរាប់គ្រូ គោលលទ្ធិ និង សេចក្តីសញ្ញា និង ប្រវត្តិសាសនាចក្រ គោលលទ្ធិនៃដំណឹងល្អ* (35685 258)និង សៀវភៅ *Our Heritage* (35448) | • | | | |
| | *Old Testament Gospel Doctrine Teacher's Manual* (35570) | | • | | |
| | *សៀវភៅសិក្សារបស់គ្រូ គោលលទ្ធិដំណឹងល្អ នៃព្រះគម្ពីរសញ្ញាថ្មី* (35681 258) | | | • | |

1. ឯកសារទាំងអស់នៅក្នុងតារាងនេះ មិនបានបកប្រែគ្រប់ភាសាទាំងអស់នោះទេ ដែលប្រើប្រាស់ កម្មវិធីមូលដ្ឋាន។ ចូរប្រើប្រាស់ ឯកសារណាដែលបើអាចប្រើបាន។ សូមទាក់ទង មជ្ឈមណ្ឌលសេវាកម្ម បើមានសំនួរពីឯកសារ ដែលបានបកប្រែហើយ។

2. *ប្រសិនបើ សៀវភៅសិក្សា បព្វជិតភាពអេរ៉ុន1* និង *យុវនារី 1* មិនបានបកប្រែ សូមប្រើសៀវភៅ *កាតព្វកិច្ច និងពរទាំងឡាយនៃ បព្វជិតភាព* សំរាប់មេរៀន សប្តាហ៍ ទីមួយទីបួន និងទីប្រាំ។

| ការជ្រើសរើសវគ្គសិក្សា | | | | | |
|---|---|---|---|---|---|
| ការបង្រៀន វគ្គសិក្សានៃដំណឹងល្អ | *សៀវភៅណែនាំសំរាប់ការបង្រៀន* (34595 258)<br>(ក្នុង 8 សប្តាហ៍ សូមមើល ទំព័រ 22–24 *សេចក្តីណែនាំសំរាប់ការបង្រៀនដំណឹងល្អ*) | • | • | • | • |
| វគ្គសិក្សា អំពី អាពាហ៍ពិពាហ៍ និង ទំនាក់ទំនងក្នុងក្រុមគ្រួសារ | *Marriage and Family Relations Instructor's Manual* (35865)<br>*Marriage and Family Relations Participant's Study Guide* (36357)<br>(ក្នុង 16 សប្តាហ៍ ត្រូវបានបង្រៀនដោយអ្នកបង្រៀន ដែលបានហៅដោយ គណៈប្រធានសាខា) | • | • | • | • |

## កម្មវិធីសិក្សាជាទូទៅសំរាប់ អង្គភាពនៃសាសនាចក្រ

(ប្រើប្រាស់នៅកន្លែងដែលសាសនាចក្រ បានបង្កើតឡើងយ៉ាងត្រឹមត្រូវ)

| **ការរៀបចំអង្គការ** | **សៀវភៅសិក្សា និង ឯកសារទាំងឡាយ** | **2005** | **2006** | **2007** | **2008** |
|---|---|---|---|---|---|
| **បព្វជិតភាពម៉ិលគីស្សាដែក និង សមាគមសង្គ្រោះ** | **សប្តាហ៍ ទី 1**<br>អ្នកដឹកនាំអាចយោងទៅលើឯកសារទាំងនេះៈ ព្រះគម្ពីរ ទស្សនាវដ្តី សាសនាចក្រ *Church Handbook of Instructions, Book 2* (35209) ជំពូក 1, 3, 7, 8, 9, និង 16, *ភាតព្វកិច្ច និងពរទាំងឡាយនៃបព្វជិតភាព ភាគ ក* (31111 258) និង*ផ្នែក ខ* (31112 258) សន្និកនារីទីវាចុងក្រោយ ផ្នែក ក (31113 258) និងផ្នែក ខ (31114 258)*គោលការណ៍ទាំងឡាយនៃ ព្រះសិក្ខាបទ* (31110 258) *Worldwide Leadership Training Meeting* booklets និងសៀវភៅ *A Member's Guide to Temple and Family History* (34697)។ | • | • | • | • |
| | សប្តាហ៍ទី 2 និង ទី3 ៈ សៀវភៅ *Teachings of Presidents of the Church* | • | • | • | • |
| | **សប្តាហ៍ទី4ៈ** ឯកសារដែលបានជ្រើសរើសដោយ គណៈប្រធានទីមួយ ការបង្រៀនសំរាប់សម័យរបស់យើង | • | • | • | • |
| | **សប្តាហ៍ទី5ៈ** ប្រធានបទ និងប្រភពធនធាន កំណត់ដោយ គណៈប៊ីស្សប | • | • | • | • |
| **បព្វជិតភាពអើរ៉ុន និង យុវនារី** | *បព្វជិតភាពអើរ៉ុនភាគ 1* (34820 258) ឬ *សៀវភៅយុវនារីភាគ 1* (34823 258) | | • | | |
| | *បព្វជិតភាពអើរ៉ុនភាគ 2* (34821 258) ឬ *សៀវភៅយុវនារីភាគ 2* (34824 258) | | | • | |
| | *បព្វជិតភាពអើរ៉ុនភាគ 3* (34822 258) ឬ *សៀវភៅយុវនារីភាគ 3* (34825 258) | • | | | • |
| **អង្គការបឋមសិក្សា** | **អាយុ 18 ខែ–3 ឆ្នាំ (ថ្នាក់ទារកដ្ឋាន និង ថ្នាក់សំរាប់កុមារតូចៗ ទាំង4)**<br>*អង្គការបឋមសិក្សាភាគ 1ៈ ខ្ញុំជាកូនរបស់ព្រះ* (34969 258) | • | • | • | • |
| | **អាយុ 4–7 (រ ផ ត 5,6,7, និង ថ្នាក់អាយុ 8)**<br>*អង្គការបឋមសិក្សាភាគ 2ៈ រើសផ្លូវត្រូវ ផ្នែក ក* (34484 258) | | • | | • |
| | *អង្គការបឋមសិក្សាភាគ 3ៈ រើសផ្លូវត្រូវ ផ្នែក ខ* (34499 258) | • | | • | |
| | **អាយុ 8–11 (ថ្នាក់ឈានមុខ អាយុ 9, 10, 11 និងថា្នក់អាយុ 12)**<br>*អង្គការបឋមសិក្សាភាគ 4ៈ ព្រះគម្ពីរមរមន* (34594 258) | | | | • |
| | *Primary 5: Doctrine and Covenants and Church History* (34602) | • | | | |
| | *Primary 6: Old Testament* (34603) | | • | | |
| | *Primary 7: New Testament* (34604) | | | • | |
| **ថ្នាក់សាលាថ្ងៃអាទិត្យ** | **អាយុ 12–13**<br>*Preparing for Exaltation Teacher's Manual* (31384) | | • | | • |
| | *The Presidents of the Church Teacher's Manual* (31382) | • | | • | |
| | **អាយុ 14 –ពេញវ័យ**<br>*ព្រះគម្ពីរមរមន ព្រះគម្ពីរមគ្គុទ្ទេសក៍ សិក្សារបស់គ្រូ* (35683 258) | | | | • |
| | *Doctrine and Covenants and Church History Gospel Doctrine Teacher's Manual* (35685) និង *Our Heritage* (35448) | • | | | |
| | *Old Testament Gospel Doctrine Teacher's Manual* (35570) | | • | | |
| | *New Testament Gospel Doctrine Teacher's Manual* (35681) | | | • | |
| | **អាយុ 14–ពេញវ័យ**<br>*គោលការណ៍ទាំងឡាយនៃ ព្រះសិក្ខាបទ* (31110 258)។ វគ្គសិក្សានេះសំរាប់សាសនាគន់ការី និងអ្នកផ្សេងទៀត ដែលចង់រៀនពី មូលដ្ឋានគ្រឹះនៃដំណឹងល្អ។ | • | • | • | • |

| **វគ្គសិក្សាដែលមានការជ្រើសរើស** | | | | | |
|---|---|---|---|---|---|
| ការបង្រៀនវគ្គសិក្សា | *Teaching, No Greater Call* (36123)<br>(សំរាប់ពេល 12 សប្តាហ៍ ជាទូទៅបង្រៀនដោយ គ្រូកែលំអសមរបសម្រួលប្រចាំវួដ) | • | • | • | • |
| វគ្គសិក្សា អាពាហ៍ពិពាហ៍<br>និង ទំនាក់ទំនងក្រុមគ្រួសារ | ”កប្រ្រងកណយ កិម ៗកងេអៀ ប្រអកងៃឲ្យិា ខ្ញុំាំ្នុតខ្សែ្រ់ា”ក្ពិកអ (35865)<br>*Marriage and Family Relations Participant's Study Guide* (36357)<br>(ក្នុង 16 សប្តាហ៍ ត្រូវបានបង្រៀនដោយអ្នកបង្រៀន ដែលបានហៅដោយ គណៈប្រធានសាខា) | • | • | • | • |
| វគ្គសិក្សាប្រវត្តិក្រុមគ្រួសារ | *A Member's Guide to Temple and Family History Work* (34697)<br>(ផ្លាស់ប្តូតាមសប្តាហ៍ ជាទូទៅបង្រៀនដោយ ក្រុមប្រឹក្សា ប្រវត្តិពង្សាវតាក្រុមគ្រួសារ) | • | • | • | • |
| វគ្គរៀបចំសំរាប់<br>ព្រះវិហារបរិសុទ្ធ | *អំណោយទានពិសិដ្ឋមកពីលើៈ មគ្គុទេសក៍ របស់គ្រូ ការរៀបចំចូលព្រះវិហារបរិសុទ្ធ* (36854 258)<br>*ការរៀបចំ ចូលព្រះវិហារបរិសុទ្ធ* (36793 258) (រយៈពេល7 សប្តាហ៍) | • | • | • | • |

© 2004 ដោយ Intellectual Reserve, Inc. រក្សាសិទ្ធគ្រប់យ៉ាង។ បោះពុម្ពនៅសហរដ្ឋអាមេរិក។ អនុមតិជាភាសា អង់គ្លេសៈ 8/03។
អនុមតិឱ្យបកប្រែៈ8/03។ ការបកប្រែនៃ *Information for Priesthood and Auxiliary Leader on Curriculum 2005 through 2008.*
Cambodian 36904 258

CAMBODIAN
4 02369 04258 3
36904 258